សហភាពអឺរ៉ុប  កម្មវិធីស្បៀងអាហារ

FAO EU Food Facility Project

# បច្ចេកទេសក្នុងការទុកដាក់ស្រូវពូជ







ធុងដាក់គ្រាប់ពូជស្រូវ

- ធុងត្រូវស្អាត និងស្ងួតមុនពេលដាក់ស្រូវ
- សំណើមគ្រាប់ស្រូវ ១១-១២ %
- រក្សាទុកធុងនៅកន្លែងម្លប់
- កម្ដៅលើគ្រាប់ស្រូវពេលហាលកុំឱ្យលើសពី ៤៣ អង្សាសេ ព្រោះវាធ្វើឱ្យគ្រាប់ពូជស្រូវមានដំណុះខ្សោយ ឬ មិនដុះ។

## ១. ការទុកដាក់ស្រូវពូជតាមទម្លាប់

ជាទូទៅ កសិករទម្លាប់ទុកដាក់គ្រាប់ពូជស្រូវក្នុងបាវ ដែលមានចំណុះចាប់ពី ៤០ ទៅ ១០០ គីឡូក្រាម ដោយដាក់នៅក្នុងផ្ទះក្បែរសរសរ ឬ ជិតមាត់ទ្វារខាងមុខ ឬ ដាក់ក្នុងជង្រុក ដែលដាក់ស្រូវចំណី។



ការទុកដាក់ស្រូវពូជក្នុងបាវ រួចដាក់ក្បែរសសរក្នុងផ្ទះ



ការទុកដាក់ស្រូវពូជក្នុងបាវ រួចដាក់ក្នុងជង្រុក

## គុណវិបត្តិនៃការទុកដាក់ស្រូវពូជតាមទម្លាប់

- អត្រាសំណើមគ្រាប់ស្រូវ ងាយនឹងឡើងចុះទៅតាមការប្រែប្រួលនៃសំណើមបរិយាកាស
- ងាយរងការបំផ្លាញពីសត្វល្អិត កណ្តុរ សត្វស្លាប និង មានជម្ងឺផ្សិត
- អត្រាដំណុះទាប (ប្រើប្រាស់ពូជច្រើន)។

## ២. ការកែលម្អបច្ចេកទេសទុកដាក់ស្រូវពូជក្នុងបរិក្ខារបិទជិត

- ✓ អត្រាសំណើមសម្រាប់ទុកដាក់ស្រូវពូជ ១១-១២%
- ✓ សមស្របនឹងអាកាសធាតុក្តៅហើយសើម (កម្ពុជា)
- ✓ ធានាបានពីការបំផ្លាញនៃសត្វល្អិត កណ្តុរ និងសត្វស្លាប
- ✓ អត្រាដំណុះខ្ពស់ (ប្រើប្រាស់ពូជតិច)។




ធុងជ័របិទជិត



ថង់ប្លាស្ទិក

### ចំណុចគួរចងចាំ

- ✓ ការទុកដាក់គ្រាប់ស្រូវនៅក្នុងបរិក្ខារបិទជិត គឺជាជំរើសល្អបំផុត ដោយហាលស្រូវឱ្យស្ងួតល្អ និងទុកដាក់ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស (កុំឱ្យត្រូវកម្តៅថ្ងៃ)
- ✓ នៅក្នុងបរិក្ខារដែលដាក់ស្រូវមិនពេញ អាចធ្វើឱ្យមាននៅសល់ខ្យល់គ្រប់គ្រាន់សម្រាប់ការរស់នៅនៃសត្វល្អិត
- ✓ ការបើក និងបិទបរិក្ខារ ឬថង់ទុកដាក់បិទជិត នឹងធ្វើឱ្យសត្វល្អិតមួយចំនួន (ដូចជា សត្វខ្ទូត) អាចចូលទៅក្នុងស្រូវសារជាថ្មី ហើយអាចចោះទម្លុះថង់ប្លាស្ទិកបាន។

## ៣. ឧបករណ៍ត្រួតពិនិត្យគុណភាពស្រូវពូជ



ឧបករណ៍វាស់សីតុណ្ហភាព




ឧបករណ៍វាស់សំណើម និងសីតុណ្ហភាព



កញ្ច្រែងរែងសត្វល្អិត និងសារធាតុលាយឡំ



ឧបករណ៍ចាក់យកសំណាក/ឆាំ

## ៤. ប្រព័ន្ធទុកដាក់ស្រូវអង្ករល្អ

①ពុំបណ្តាលឱ្យស្រូវដែលស្ងួតស្រូបសំណើមឡើងវិញ ②ការពារបាននូវសត្វល្អិត កណ្តុរ និងសត្វស្លាប ③ងាយស្រួលចាក់ ឬ ដាក់ស្រូវចូល ឬ យកចេញ និង ④ងាយស្រួលថែរក្សា និងគ្រប់គ្រង ។

**មករា ឆ្នាំ ២០១១**

រៀបចំដោយ: នាយកដ្ឋានគ្រឿងយន្តកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម
អាស័យដ្ឋាន: អគារលេខ ៤៥ បេ ផ្លូវលេខ ៦៥៦ សង្កាត់ទឹកល្អក់ទី ៣ ខណ្ឌទួលគោក ភ្នំពេញ

ទូរស័ព្ទ: ០២៣ ៨៨ ៣២ ៦៧ និង ០២៣ ៨៨ ៣០ ៩០